 

# សង្គ្រាម

# កម្ពុជា - វៀតណាម

## (១៩៧៥-១៩៨៩)

## ▪ សេចក្តីផ្តើម

**សង្គ្រាមកម្ពុជាវៀតណាម** គឺជាការប៉ះទង្គិចប្រដាប់អាវុធរវាងសាធារណរដ្ឋសង្គមនិយមវៀតណាម និង កម្ពុជាប្រជាធិបតេយ្យ។ សង្គ្រាមនេះបានចាប់ផ្តើម ជា មួយការប៉ះទង្គិចដោយឡែកគ្នាតាមរយៈព្រំដែនគោក និងសមុទ្រវៀតណាម និងកម្ពុជារវាងឆ្នាំ១៩៧៥ និង១៩៧៧ ជូនកាលមានការពាក់ ព័ន្ធនឹងការបង្កើត កង ទ័ពទំហំស្មើកងពលធំ ។ ថ្ងៃ២៥ធ្នូ១៩៧៨ វៀតណាមបានផ្តើមការលុកលុយ កម្ពុជាពេញទីនិងជាបន្ត បន្ទាប់បានកាន់កាប់ប្រទេសនេះបន្ទាប់ពីខ្មែរក្រហមត្រូវបានដកចេញពីអំណាច។ កំឡុងសង្គ្រាមវៀតណាម ពួកកុម្មុយនិស្តវៀតណាម និងខ្មែរ ក្រហមបានបង្កើតសម្ព័ន្ធភាពមួយដើម្បីប្រឆាំង នឹងរបបដែលមាន ស.រ.នៅពីក្រោយខ្នងក្នុងប្រទេស ពួកគេរៀងខ្លួន។ ទោះបីជាការបង្ហាញ ជាចំហ របស់ខ្លួននូវការសហការជាមួយពួកវៀតណាមមែនពួកមេដឹកនាំខ្មែរក្រហម បានភ័យ ខ្លាច ថាពួកកុម្មុយនិស្តវៀតណាមកំពុងតែមានគម្រោង ដើម្បីបង្កើតសហព័ន្ធឥណ្ឌូចិនដែលមានវៀតណាមជាកម្លាំងត្រួតត្រាក្នុងតំបន់ នេះ ។ ដើម្បីយកអោយបានការ ប៉ុនប៉ងមុនដោយពួកវៀតណាមដើម្បីត្រួត្រាខ្លួន ពួកមេដឹកនាំខ្មែរក្រហមក៏បានចាប់ផ្តើមបន្សុទ្ធកម្ម បុគ្គលិកដែលបង្ហឹកដោយវៀតណាម ក្នុងជួររបស់ពួកគេពេលដែលរបបលន់-ណុលបានចុះចាញ់នៅឆ្នាំ ១៩៧៥។ បន្ទាប់មក នៅខែ ឧសភា ១៩៧៥ កម្ពុជាប្រជាធិបតេយ្យដែលបានបង្កើតថ្មីមួយនេះ បានត្រួត្រាដោយ ពួកខ្មែរ ក្រហម បានចាប់ផ្តើមបង្កសង្គ្រាមប្រឆាំង នឹងវៀតណាម ដែលត្រូវបានកត់សម្គាល់តាមរយៈការវាយប្រហារលើកោះវៀតណាមភូគុក (កោះត្រល់) ។ ទោះបីជាការ ប្រយុទ្ធ គ្នា ដែលបានកើតឡើងរវាងប្រទេសទាំងពីរនេះក៏ដោយ ក៏ពួកមេដឹកនាំនៃវៀតណាមនិងកម្ពុជារួបរួមគ្នា ឡើងវិញដែលបង្កើត ជា ការដោះ ដូរការទូត ជា សាធារណៈច្រើនលើកច្រើនសា ពេញមួយឆ្នាំ១៩៧៦ ដើម្បីធ្វើឱ្យលេចឡើងទំនាក់ទំនងរឹងមាំដោយសង្ឃឹមទុករវាងពួកគេ ។ នៅពីក្រោយឆាក យ៉ាងណាក៏ ដោយ ក៏ពួកមេដឹកនាំកម្ពុជាបានបន្តភ័យនូវអ្វីដែលខ្លួនបានសង្កេតថាជាការវាតទីនិយម រឺ វិត្តានិយម របស់វៀតណាម ។ ដូចគ្នាដែរ នៅថ្ងៃ៣០មេសា ១៩៧៧ ពួកគេបានផ្តើមការវាយប្រហារយោធាដ៏ធំមួយផ្សេងទៀតលើវៀតណាម ។ ដោយបានតក់ស្លុតតាមរយៈការវាយសម្រុកចូលរបស់កម្ពុជា វៀតណាមក៏បានផ្តើម ការវាយប្រហារសងសឹកមួយវិញនៅចុងឆ្នាំ១៩៧៧ ក្នុងបំណងមួយដើម្បីបង្ខំអោយរដ្ឋាភិបាលកម្ពុជាចរចារ ។ នៅខែ មករា ១៩៧៨ កងទ័ពវៀតណាមបាន ដក ថយព្រោះគោលដៅនយោ បាយរបស់ខ្លួនមិនបានសម្រេច ។ការវាយប្រហារគ្នាទ្រង់ទ្រាយតូចបានបន្តរវាងប្រទេសទាំងពីរពេញមួយឆ្នាំ១៩៧៨ ដូចគ្នាចិនបាន ព្យា យាមសម្រុះសម្រួលឱ្យមានការជជែកពិភាក្សា

សន្តិភាពរវាងប្រទេសទាំងពីរខាង ។ យ៉ាងណាៗ ប្រទេសណាក៏មិនអាចឈាន ដល់ការ សន្យា ដែលអាចទទួល យកបាននៅតុចរចារឡើយ ។ នៅចុងឆ្នាំ១៩៧៨ ពួកមេដឹកនាំវៀតណាមបាន សម្រេច ចិត្តរបបកម្ពុជា ប្រជាធិប តេយ្យ ដែលត្រួតត្រាដោយខ្មែរក្រហម ដោយ សង្កេតថារបប នេះជារបបនិយមចិន និងមានអរិភាពខ្លាំងចំពោះវៀតណាម។ ថ្ងៃ២៥ធ្នូ ១៩៧៨ ទ័ពវៀតណាម ១៥០០០០នាក់បាន លុកលុយកម្ពុជា ប្រជាធិប តេយ្យ និងបានវាតត្បាតកងទ័ពបដិវត្តន៍កម្ពុជា ក្នុងរយៈ ពេលត្រឹម តែ ពីរអាទិត្យតែប៉ុណ្ណោះ ។ ថ្ងៃ៨មករា ១៩៧៩ សាធារណរដ្ឋប្រជាមានិតកម្ពុជានិយមវៀតណាម (ស.ប.ក.)ត្រូវបានបង្កើតឡើង នៅភ្នំ ពេញ ដែលកត់សម្គាល់នូវការផ្តើម ការកាន់កាប់របស់វៀតណាមរយៈពេលដប់ឆ្នាំ ។ អំឡុងសម័យកាលនោះ កម្ពុជា ប្រជាធិប តេយ្យ របស់ខ្មែរក្រហមត្រូវបានទទួលស្គាល់ដោយអង្គការសហប្រជាជាតិជារដ្ឋាភិបាលស្របច្បាប់ នៃកម្ពុជា ដូចគ្នាដែរក្រុមតស៊ូប្រដាប់ អាវុធ ជាច្រើនត្រូវបាន បង្កើតឡើងដើម្បីប្រយុទ្ធប្រឆាំងនឹង ការកាន់កាប់របស់វៀតណាម ។ នៅពីក្រោយឆាកទាំងនេះ លោកនាយករដ្ឋ មន្ត្រី ហ៊ុន- សែន នៃរបបស.ប.ក. បានខិតជិតក្រុម នៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ (រ.ច.ក.ប.)ដើម្បី ចាប់ផ្តើមការជជែក ពិភាក្សា សន្តិភាព។ នៅក្រោមសម្ពាធការទូតនិងសេដ្ឋកិច្ចយ៉ាងធ្ងន់ ពីសហ គមន៍ អន្តរជាតិ រដ្ឋាភិបាលវៀតណាមបានអនុវត្ត ជាបន្តបន្ទាប់នូវ កំណែទម្រង់សេដ្ឋកិច្ច និង គោលនយោបាយការបរទេស ដែលនាំទៅដល់ការដក ទ័ពរបស់ ខ្លួនពី កម្ពុជាក្នុងខែកញ្ញា ១៩៨៩ ។នៅក្នុង ជំនួប ក្រៅផ្លូវការចាកាតាលើកទីបីនៅឆ្នាំ១៩៩០ ក្រោមផែនការសន្តិភាពកម្ពុជា ដែលឧបត្ថម្ភដោយអូស្ត្រាលី ពួកអ្នកតំណាង នៃ រ.ច.ក.ប. និងស.ប.ក.បានយល់ព្រមការរៀបចំ អោយមានការបែងចែកអំណាចគ្នាដោយការបង្កើតរដ្ឋាភិបាលរួបរួមគ្នាដែលគេស្គាល់ ថាជា ឧត្តមក្រុមប្រឹក្សាជាតិ (ឧ.ក.ជ.)។ តួនាទីឧ.ក.ជ.ដើម្បីតំណាងអធិបតេយ្យភាពកម្ពុជាលើឆាកអន្តរ ជាតិ ដែលកាលណោះអាជ្ញាធរ អន្តរកាលសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់ រឺ អ.អ. ស.ប.ក.) ត្រូវទទួលបន្ទុកជាមួយការត្រួតពិនិត្យគោលនយោបាយក្នុងស្រុករបស់ ប្រទេសនេះរហូតដល់រដ្ឋាភិបាលកម្ពុជា ត្រូវបានបោះឆ្នោត ដោយប្រជាជនតាម រយៈដំណើរការសន្តិភាព ប្រជាធិបតេយ្យ ។ ផ្លូវលំ កម្ពុជាដើម្បីសន្តិភាពបានបង្ហាញថាមានការលំបាក ពេលដូចគ្នាពួកមេដឹកនាំខ្មែរ ក្រហម បានសម្រេច ចិត្តមិន ចូលរួម នៅក្នុងការបោះ ឆ្នោតសកល ប៉ុន្តែជំនួសមកវិញ ពួកគេ បានជ្រើសយករំខានដំណើរការការបោះឆ្នោតដោយផ្តើមការវាយ ប្រហារយោធា លើពួកអ្នកថែ រក្សាសន្តិភាព និងសម្លាប់ជនអន្តោប្រវេសន៍ជនជាតិយួន ។ នៅខែឧសភា ១៩៩៣ ចលនា ហ្វ៊ុនស៊ិនប៉ិចរបស់ព្រះសីហនុ បានផ្តួល គណបក្សប្រជាជនកម្ពុជា (គ.ប.ក.) អតីតបក្សបដិវត្តន៍ ប្រជាជនកម្ពុជា (ប.ប.ប.ក.) ដើម្បីឈ្នះការបោះឆ្នោតសកល។ ក៏ប៉ុន្តែ ពួកមេដឹក នាំគ.ប.ក. បាន បដិសេធទទួលយកការ បរាជ័យ ហើយពួកគេបានប្រកាសខេត្តភាគខាងកើតកម្ពុជា ដែលជាទី

ដែលភាគច្រើននៃ សម្លេង របស់គ.ប.ក.ដែលស្រូបទាញបានពីទីនោះនឹងធ្វើអបគមន៍ចេញពីកម្ពុជា។ ដើម្បីចៀសវាងលទ្ធផលដូច្នេះព្រះអង្គម្ចាស់នរោត្តម-រណឫទ្ធិ មេដឹកនាំហ៊្វុនស៊ិនប៉ិចបានយល់ព្រមអោយបង្កើតរដ្ឋាភិបាលចម្រុះជាមួយគ.ប.ក.។ រយះពេលដ៏ខ្លីតមកទៀត រាជាធិបតេយ្យ អាស្រ័យ រដ្ឋធម្មនុញ្ញត្រូវបានស្តារឡើង និងពួកខ្មែរក្រហមត្រូវស្ថិតនៅក្រៅច្បាប់ដោយរដ្ឋាភិបាលកម្ពុជាបង្កើតថ្មី ។

- ## ផ្ទៃរឿង

### ប្រវត្តិសាស្ត្រខ្មែរ-យួន

អង្គរ អាសនៈនៃអធិរាជាណាចក្រខ្មែរត្រូវដាក់នៅក្រោមឥទ្ធិពលយួនដូចគ្នានៅដើមសតវត្សទី១៥។ ឥទ្ធិពលយួនបានរីកសាយភាយ យឺតៗ និងដោយប្រយោល ហើយវាមិនរហូតដល់ដើមសតវត្សទី១៩ទេដែលយួនបានប្រើប្រាស់ការគ្រប់គ្រងដោយផ្ទាល់។ នៅឆ្នាំ១៨១៣ អ្នកអង្គចន្ទបានទទួលបានរាជបល្ល័ង្កជា មួយការ ជួយជ្រោមជ្រែងពីយួន ហើយក្រោមការគ្រប់គ្រងរបស់ទ្រង់កម្ពុជាប្រែក្លាយជា ប្រទេស ក្រោមអាណាព្យាបាល។ បន្តបន្ទាប់ពីការសោយទីវង្គតរបស់ទ្រង់នៅឆ្នាំ ១៨៣៤ យួនបានធ្វើអាណានិគមកិច្ចកម្ពុជាដែលត្រូវបានដាក់ ការគ្រប់គ្រងក្រោមរដ្ឋបាលយួននិងបានកំណត់ក្នុងលក្ខខណ្ឌ'ខេត្ត'យួន។ពេញមួយទសវត្សឆ្នាំ ១៨៣០ យួនព្យាយាមលុបបំបាត់វប្បធម៌ ខ្មែរ ដែលបានមកពីមូលដ្ឋានគ្រឹះនៃសង្គម សម្លៀកបំពាក់កម្ពុជា និងសាសនាមកពីឥណ្ឌាផ្ទុយស្រឡះពីចិន។ និន្នាការ នៃភាពត្រួតត្រា របស់យួនបានបន្តកំឡុងសម័យអាណានិគមកិច្ចរបស់បារាំង ក្រោមយួនដែលកម្ពុជាត្រូវបង្ខំអោយប្រគល់ភាគច្រើននៃកោណភាគខាងត្បូង របស់ ខ្លួន (នឹងក្រោយមកទៀតគឺសៃហ្គន ដីសណ្តរមេគង្គ និងតៃនិញ) ទៅពួកយួន។ ពួកខ្មែរក្រហមក្រោយមកបានធ្វើយុត្តិកម្មការ លុកលុយ របស់ខ្លួនចូល ទៅ វៀតណាមតាមរយៈការប៉ុនប៉ងដើម្បីដណ្តើមទឹកដីនេះវិញ ដែលកម្ពុជាបានបាត់បង់កំឡុងប៉ុន្មានសតវត្ស មុនៗ ។

- ## ការរងើបឡើងនៃលទ្ធិកុម្មុយនិស្ត

ចលនាកុម្មុយនិស្តនៅកម្ពុជានិងវៀតណាមបានចាប់ផ្តើមពីមុនសង្គ្រាមលោកលើកទី២ជាមួយការស្ថាបនាបក្សកុម្មុយនិស្តឥណ្ឌូចិន(ប.ក.ឥ.) ស្ទើរតែទាំងស្រុង លើសលប់បានត្រួតត្រាដោយពួកវៀតណាម ដើមឡើយក្នុងអត្តន័យដើម្បីប្រយុទ្ធប្រឆាំងនឹងការគ្រប់គ្រង អាណានិគមរបស់បារាំងនៅឥណ្ឌូចិន។ នៅឆ្នាំ១៩៤១ ង្វៀន-អាយឃ្វក(ដែលគេស្គាល់ជាសាមញ្ញតាមឈ្មោះហៅក្រៅរបស់លោកហូ-ជីមិញ) បានបង្កើត វៀតណាមដុកឡឹបដុងមីញហ៊ាយ រឺ វៀតមិញ ។

នៅពេលនោះ ពួកជប៉ុនបានចាញ់នៅចុងសង្គ្រាមលោកលើកទី២ លោកក៏បានផ្តើមគំនិតអោយមានសង្គ្រាមឥណ្ឌូចិនលើកទីមួយដើម្បីឯករាជ្យប្រឆាំងទល់នឹងពួកបារាំង។ អំឡុងពេលនោះ កងទ័ពវៀត ណាមបានធ្វើការប្រើប្រាស់ដីធំធេងនៃទឹកដីកម្ពុជាដើម្បីដឹកជញ្ជូនសព្វាវុធ គ្រឿងផ្គត់ផ្គង់ និងកងទ័ព ។ ទំនាក់ទំនងនេះបានបន្តពេញ មួយសង្គ្រាមវៀតណាមនេះ នៅពេលនោះ ពួកកុម្មុយនិស្តវៀតណាមបានប្រើប្រាស់កម្ពុជាចាផ្លូវដឹកជញ្ជូននិងតំបន់ឆាកប្រយុទ្ធសម្រាប់ ការវាយប្រហារលើ វៀត ណាម ខាងត្បូង ។ នៅឆ្នាំ១៩៥១ វៀតណាមបានដឹកនាំអោយមានការបង្កើតបក្សកុម្មុយនិស្តកម្ពុជាអោយនៅ ដោយទ្បែកគឺបក្សបដិវត្តន៍ប្រជាជនកម្ពុជា(ប.ប.ប.ក.) ដែលបានចងសម្ព័ន្ធភាពជាមួយចលនាបំបែកខ្លួនពីអ្នកជាតិនិយមខ្មែរសេរី ដើម្បី ស្វែងរកឯករាជ្យ ។ ដោយអនុលោមជាមួយកិច្ច សម្រុះសម្រួល សឺណែវ១៩៥៤ដែលកំពុងចរចារនូវការបញ្ចប់ការត្រួតត្រា របស់បារាំង វៀតណាមខាងជើងកុម្មុយនិស្តដែលបង្កើតថ្មីបាន ដកពួកទាហាននិង កម្មាភិបាលរបស់ ខ្លួនចេញពីកម្ពុជា យ៉ាងណាៗ ដោយហេតុថា ប.ប.ប.ក.ត្រូវបានផ្តល់បុគ្គលិកដំបូងដោយជនជាតិយួន រឺ ពួកខ្មែរស្ថិតនៅក្រោមការទំនុកបម្រុងរបស់ខ្លួន ប្រហែលពួកកម្មាភិបាល កុម្មុយនិស្ត៥០០០នាក់ក៏បានទៅជាមួយពួកគេដែរ។ថាមពលនេះស្រូបទាញពួកកុម្មុយនិស្តយួនដែលសេសសល់អោយមានការឱ្យភ្ញាក់ ឡើងនៅ កម្ពុជាដែលមិនយូរមិនឆាប់បានបំពេញតាមរយៈការត្រឡប់មកវិញនៃក្រុមជនបដិវត្តន៍កម្មុយនិស្តកម្ពុជាក្មេង ភាគច្រើននៃពួកគេបានទទួលការអប់ រំលទ្ធិកុម្មុយ និស្តនៅបារាំង។ នៅឆ្នាំ១៩៦០ ប.ប.ប.ក.បានប្តូរឈ្មោះទៅជាបក្សកម្មុយនិស្តកម្ពុជា (ប.ក.ក.) និងឈ្មោះនេះក្រោយមកទៀតត្រូវបាន រើសយកដោយ ក្រុមចម្រុះ ភាគច្រើនដែលបង្កើតឡើននៅក្បែរៗ សាឡុត-ស (ប៉ុល-ពត) អៀង-សារី និងខៀវ-សំផនជាស្ថាប័ននយោបាយ 'ពិត'ដែលរំលឹកដល់ប.ក.ក. ។ បននេះបានក្លាយ ជាកំណើតនៃពួកខ្មែរក្រហម និងលទ្ធិរបស់បននេះគឺត្រូវទទួលរងឥទ្ធិពលយ៉ាងខ្លាំងដោយមនោគមវិជ្ជាម៉ៅនិយម។

- *កម្ពុជាប្រជាធិបតេយ្យ និង ខ្មែរក្រហម*

រដ្ឋាភិបាលខ្មែរក្រហមបានជ្រើសយកពាក្យសម្ងាត់*អង្គការ* និងរហូតដល់ឆ្នាំ១៩៧៧ អត្តសញ្ញាណនៃពួកមេដឹកនាំរបស់អង្គការ នៅ តែអាថ៌កំបាំង ។ប្រមុខរដ្ឋផ្លូវការ គឺខៀវ-សំផន ប៉ុន្តែមនុស្សពីរនាក់ដែលនៅក្នុងអំណាចគឺប៉ុល-ពត និងអៀង-សារី។ គោលដៅចុង ក្រោយនៃខ្មែរក្រហមគឺលុបចោលរចនាសម្ព័ន្ធរដ្ឋកម្ពុជា ដែល ពួកខ្លួនមើលឃើញថាជាសក្តិភូមិ មូលធននិយម និងបានតម្រង់ទិសដៅ ជុំវិញរបៀបវារៈនៃពួកឥស្សរជនដែលកំពុងកាន់កាបដី និពួកចក្រពត្តិនិយម ។ ជាការ ជំនួសវិញ ពួកគេសង្ឃឹមដើម្បីបង្កើតសង្គមគ្មាន វណ្ណៈដែលផ្អែកទាំងស្រុកលើពួកកម្មករ កសិករ ។ មនោគមវិជ្ជាដាច់ខាងនិងគោល ដៅនៃពួកខ្មែរ ក្រហម គឺជា ទស្ស

នាទានដ៏ ចម្លែក ចំពោះមនុស្សភាគច្រើន។ ជាការពិត បដិវត្តន៍សង្គមនិយមបានប្រកាន់យកការសុំអង្វរអំពាវនាវរបស់ប្រជាជនតិចតួចណាស់ ដែល នាំអោយ ប៉ុល-ពត និងពួកកម្មាភិបាលរបស់គាត់ប្រើមនោសញ្ចេតនាជាតិនិយមយ៉ាងលើសលប់ ការដឹកនាំដោយសង្កត់សង្កិន និងដោយឃាតកម្ម និងការឃោសនាមាន បំណងបង្ហាញនូវភាពអាក្រក់ពួកវៀតណាមដើម្បីថែរក្សាអំណាចមិនរឹងប៉ឹងរបស់ខ្លួន។ កំឡុង ប្រាំឆ្នាំនៃឧទ្ទាមកម្មខ្មែរក្រហមពីឆ្នាំ១៩៧០ដល់១៩៧៥ ការគាំទ្រ របស់វៀតណាមខាងជើង ជាការប្រសព្វគ្នាជាមួយចិនដែលចាំបាច់ ដើម្បីជ័យជម្នះចុងក្រោយរបស់ខ្លួន ។ យ៉ាងណាក៏ដោយ ទោះបីជាមុនសង្គ្រាម វៀតណាម បានបញ្ចប់ ទំនាក់ទំនងរវាងខ្មែរក្រហម ដែលគឺជាដំណើរការនៃការដណ្តើមអំណាចពីរបបដែលមានស.រ.នៅពីក្រោយខ្នងដឹកនាំដោយលន់-ណុល និងវៀតណាម ក៏មានការ តឹងតែងដែរ។ ការប៉ះទង្គិចគ្នារវាងពួកកុម្មុយនិស្តវៀតណាមនិងកងកម្លាំងខ្មែរក្រហមបានចាប់ផ្តើមដំណាលគ្នានៅដើមឆ្នាំ១៩៧៤និងឆ្នាំ បន្តបន្ទាប់ ប៉ុល-ពតបានចុះហត្ថលេខាលើសន្ធិសញ្ញាដែលធ្វើឱ្យរៀបរយ 'មិត្តភាព' រវាងខ្មែរក្រហម និងចិន។

- *ការទូត និង សកម្មភាពយោធា*

## ១៩៧៥–៧៦ ចាប់ពីការប្រយុទ្ធរហូតដល់ការសាងទំនាក់ទំនងជាមិត្ត

ទីបញ្ចប់នៃការប៉ះទង្គិចនៅឥណ្ឌូចិននៅខែមេសា១៩៧៥ភ្លាមៗនោះបាននាំមកដល់ការប៉ះទង្គិចថ្មីមួយទៀតរវាងវៀតណាម និង កម្ពុជា ។ ទោះបីជាយ៉ាងណា ទាំងវៀតណាមខាងជើងនិងខ្មែរក្រហមក៏បានប្រយុទ្ធកៀកស្មាគ្នាពីមុនមកដែរ ពួកមេដឹកនាំនៃកម្ពុជា ប្រជាធិបតេយ្យ ដែលបាន បង្កើតថ្មីបានបន្ត មើលឃើញថា វៀតណាមខាងជើងដោយការសង្ស័យយ៉ាងខ្លាំង ព្រោះតែពួកខ្លួនមាន ជំនឿថាពួកកុម្មុយនិស្តវៀតណាមមិន ដែលបានបោះបង់ចោល សុបិនរបស់ពួកគេក្នុងការ បង្កើតសហព័ន្ធឥណ្ឌូចិនដែលមានវៀត ណាម ជាមេដឹកនាំឡើយ។ ដោយហេតុផលនេះ រដ្ឋាភិបាលកម្ពុជាបានសម្រេចចិត្ត ដកកងកម្លាំងយោធាវៀតណាម ខាង ជើងទាំងអស់ ពីទឹកដីកម្ពុជាក្នុងរយៈពេលខ្លីបន្ទាប់ពីការកាន់កាប់ភ្នំពេញបាននៅឆ្នាំ១៩៧៥។ ការប៉ះទង្គិចគ្នាដ៏សំខាន់លើកដំបូងរវាង អតីតសម្ព័ន្ធមិត្ត ទាំងពីរ កងទ័ពបដិវត្តន៍កម្ពុជាបានលុកលុយកោះភូគុកវៀតណាមនៅថ្ងៃ១ឧសភា១៩៧៥ដែលពួកគេអះអាងថាជាផ្នែកនៃទឹកដីកម្ពុជា។

ប៉ុល-ពតគឺជាមេដឹកនាំខ្មែរក្រហម។ បន្តបន្ទាប់ពីជ័យជម្នះខ្មែរក្រហមនៅថ្ងៃ១៧មេសា១៩៧៥ គាត់បានក្លាយជារដ្ឋមន្ត្រីប្រមុខនៃ កម្ពុជាប្រជាធិបតេយ្យនិង បាន ដឹកនាំប្រទេសគាត់ចូលក្នុងសង្គ្រាមប្រឆាំងនឹងវៀតណាម។៩ថ្ងៃក្រោយមក នៅថ្ងៃ១០ឧសភា១៩៧៥កង ទ័ពកម្ពុជាបានបន្តការ

លុក លុយរបស់ខ្លួន ដោយការ កាន់កាប់ថូកចឹរ ជាកន្លែងដែលបានសម្លាប់អសេនិកជនយួន ៥០០នាក់។ កងទ័ព វៀតណាមបានឆ្លើយតបភ្លាមៗទៅនឹងសកម្មភាពរបស់កម្ពុជា ដោយការវាយ ប្រហារតបតវិញ និងរុញច្រានកងទ័ពកម្ពុជា ពីភូគុកនិង ថូកចឹរ ហើយក្រោយមកក៏លុកលុយកោះប៉ូឡូវៃកម្ពុជា ។ នៅខែមិថុនា១៩៧៥ កាលណោះ ចំពេល ទស្សនកិច្ចទៅហាណូយ មេដឹកនាំ កម្ពុជាប៉ុល-ពតបានស្នើថាវៀតណាមនិងប្រទេសរបស់គាត់គួរតែចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពមួយ និងចាប់ផ្តើមការ ពិភាក្សា លើជម្លោះព្រំដែន។យ៉ាងណាក៏ដោយ ការពិភាក្សាអស់ទាំងនេះមិនដែលបានធ្វើឱ្យចេញជារូបរាងទេហើយពួកខ្មែរបានអះអាងថាវៀតណាមបាន បដិសេធសំនើទាំងពីរ។ នៅខែសីហា១៩៧៥ វៀតណាមបានប្រគល់កោះប៉ូឡូវៃអោយកម្ពុជាវិញនិង ទទួលស្គាល់អធិប តេយ្យភាពកម្ពុជាជាផ្លូវការលើកោះនេះ ។បន្តបន្ទាប់ពីឧប្បត្តិហេតុទាំងនោះមក ប្រទេសទាំងពីរបានប៉ុនប៉ងបង្កើនទំនាក់ទំនងទូតរបស់ ខ្លួន ជាមួយសារអបអរសាទរ ជាបន្តបន្ទាប់ និងការដោះដូរ ទស្សន កិច្ចគ្នា។ ថ្ងៃ១៧មេសា ១៩៧៦ ពួកមេដឹកនាំវៀតណាមបានបញ្ជូន សារមួយដើម្បីអបអរសាទរ ខៀវ-សំផន នួន-ជា និងប៉ុល-ពតទៅលើការបោះឆ្នោតពួកគាត់ ធ្វើ ជាប្រធាន ប្រធានពួកអ្នកតំណាង ប្រ ជាជន និងរដ្ឋមន្ត្រីប្រមុខនៃកម្ពុជារៀងខ្លួន។ បន្ថែមទៀត ពួកវៀតណាមថែម ទាំងបាន ថ្កោលទោសការទម្លាក់គ្រាប់ បែកស.រ.ដែលបានពោលអះអាងនៅសៀមរាបនៅខែកុម្ភៈ១៩៧៦ ដោយហេតុនោះក៏ធ្វើអោយមានការអះអាងដែលសន្មតរបស់កម្ពុជា បន្ថែមលើ ឧប្បត្តិហេតុនេះ ។ ជាការ ឆ្លើយតបវិញ នៅខែមិថុនា ១៩៧៦ ពួកមេដឹកនាំកម្ពុជា បានបញ្ជូនសារមួយដល់រដ្ឋាភិបាល បដិវត្តន៍បណ្តោះ អាសន្នសាធារណរដ្ឋវៀតណាមខាងត្បូង ដែលបានគ្រប់គ្រងវៀតណាមខាងត្បូងតាំងតែពីការធ្លាក់របបដែលមានស.រ.នៅពីក្រោយខ្នង ដោយការអបអរពួកគេលើខួបអនុស្សាវរីយ ទីប្រាំពីរនៃការបង្កើតឡើង របស់ ខ្លួន។នៅខែកក្កដា១៩៧៦បន្តបន្ទាប់ពីការបង្កើតនូវសាធា រណរដ្ឋសង្គមនិយមវៀតណាមពេលដែលប្រទេសរួបរួមគ្នាឡើងវិញ វិទ្យុភ្នំ ពេញបានផ្សាយបទវិចារណកថាដែលបានប្រកាសសាមគ្គី ភាពនិងមិត្តភាពសកម្មប្រយុទ្ធរវាងប្រជាជនកម្ពុជាប្រជាធិបតេយ្យនិងសាធារណរដ្ឋសង្គមនិយមវៀតណាមដែលកាន់តែស្រស់ត្រកាល និងរឹងមាំជានិច្ចឥតឈប់ឈរ។យ៉ាងណាក៏ដោយ កំឡុងខែដដែលនោះ រដ្ឋមន្ត្រីប្រមុខប៉ុល-ពត បានប្រលយពាក្យអោយឃើញនូវ ភាព តានតឹងរវាងវៀតណាមនិងកម្ពុជា ដែលនោះពេលនោះ គាត់បានប្រាប់គណៈប្រតិភូប្រព័ន្ធផ្សព្វផ្សាយវៀតណាមដែលកំពុងធ្វើ ទស្សន កិច្ច ថាមាន ឧបសគ្គ និងភាពលំបាកនៅក្នុងទំនាក់ទំនងភាពរវាងប្រទេសទាំងពីរ ។ មិនត្រឹមតែប៉ុណ្ណោះទេ នៅថ្ងៃ២១កញ្ញា ១៩៧៦ ការ ភ្ជាប់សេវាអាកាសចរណ៍ដំបូងហាណូយនិងទីក្រុងហូជីមិញជាមួយភ្នំពេញត្រូវបាន

បង្កើតឡើង ។ ក្រោយមក ទៀតនៅខែធ្នូ១៩៧៦ អង្គ ការ បដិវត្តន៍កម្ពុជាបានបញ្ជូនពាក្យស្វាគមន៍ដល់បក្សកុម្មុយនិស្តវៀតណាមកំឡុងសមាជលើកទីបួនរបស់ពួកគេ។

- *១៩៧៧ ការវិវត្តបន្តិចម្តងៗទៅកាន់សង្គ្រាម*

ឆ្ពោះទៅចុងនៃឆ្នាំ១៩៧៦ គ្រានោះវៀតណាមនិងកម្ពុជាបានមើលឃើញជាសាធារណៈកំពុងតែបង្កើតចំណងមេត្រីភាពរបស់ខ្លួន ការមន្ទិលសង្ស័យឯកឯងនៃ ពួកមេដឹកនាំប្រទេសទាំងពីរបានកើនឡើង។ ដោយទស្សនវិស្ស័យវៀតណាម ពួកគេគឺជា អ្នកគាំទ្រដល់ បដិវត្តន៍ម៉ាក្សនិយម-លេនីននិយមពិតប្រាកដនៅអាស៊ីអាគ្នេយ៍ដូច្នេះវាសំខាន់ណាស់ចំពោះពួកគេប្រើការគ្រប់គ្រងលើពួកខ្មែរនិងលាវ។ ពិតមែនហើយនោះគឺជាហេតុផលដែលវៀតណាម ខាងជើងបានគាំទ្រ ដល់ពួក ខ្មែរក្រហមកំឡុងពេលការប្រយុទ្ធរបស់ ពួកគេប្រឆាំង នឹងរបបលន់-ណុល ក្នុងក្តីសង្ឃឹមថាពួកកុម្មុយនិស្តកម្ពុជានឹងរក្សាទុកខ្សែបណ្តាញដែលនិយម វៀតណាមលើជ័យជម្នះរបស់ខ្លួនក្នុងវិធី ដូចគ្នាដែរ ដែលបទេសលាវបានធ្វើរួច។ ។ យ៉ាងណាមិញ ក្តីសង្ឃឹមរបស់ពួកគេត្រូវបានសាបសូន្យដូចគ្នានៅដើមឆ្នាំ១៩៧៣ពីព្រោះការ បង្កបង្កើតយោធាវៀតណាមខាងជើងកំពុងតែប្រតិបត្តិការនៅក្នុងទឹកដីដែលកាន់កាប់ដោយខ្មែរក្រហមជួនកាលត្រូវបានស្ថិតនៅក្រោម ការវាយប្រហារប្រដាប់ អាវុធដោយសម្ព័ន្ធមិត្តរបស់ពួកគេ។ តំណែងរបស់វៀតណាមនៅខាងក្នុងកម្ពុជាកាន់តែចុះខ្សោយ បន្ទាប់ពីការ បញ្ចប់សង្គ្រាមនេះ ពេលដូចគ្នានេះដែរ គ្មានធាតុនិយមវៀតណាម នៅសេសសល់នៅខាងក្នុងបក្សកុម្មុយនិស្តកម្ពុជាទៀតឡើយ។ដូច្នេះហើយ នៅពេលប៉ុល-ពតដែលនិយមចិន និងបងប្អូនថ្លៃរបស់គាត់អៀង-សារីបានលាលែងតំណែងជារដ្ឋមន្ត្រី ប្រមុខនិងរដ្ឋមន្ត្រីការ បរ ទេសរៀងៗខ្លួននៅខែកញ្ញា១៩៧៦ នាយករដ្ឋមន្ត្រីវៀតណាមផាម-វ៉ាន់ឌុងនិងអគ្គលេខាធិការបក្សកម្មុយនិស្តឡេ-ដ្វឺនមានសុទិដ្ឋិនិយម ថាវៀតណាមអាចប្រើឥទ្ធិពលកាន់តែខ្លាំងលើពួកខ្មែរ។ ក្នុងជំនួបឯកជនជាមួយឯកអគ្គរដ្ឋទូតសូវៀតទៅវៀតណាម នៅថ្ងៃ១៦ វិច្ឆិកា ១៩៧៦ ឡេ-ដ្វឺនបានបដិសេធ ចោលទាំងអៀង-សារីនិងប៉ុល-ពតថាជាជនអាក្រក់ចំពោះគោលនយោបាយនិយមចិនរបស់ពួកគាត់។ ឡេ-ដ្វឺន ក្រោយមកបាននិយាយអះអាងថានួន-ជា ជាអ្នកដែលឡើងកាន់តំណែងរដ្ឋមន្ត្រីប្រមុខនៃកម្ពុជាប្រជាធិបតេយ្យជំនួសប៉ុល-ពត គឺជាមនុស្សម្នាក់ក្នុងការដឹកនាំដែលនិយមវៀតណាម ដូច្នេះវៀតណាមអាចប្រើឥទ្ធិពលរបស់ខ្លួនតាមរយៈគាត់។ យ៉ាងណាមិញ ព្រឹត្តិ ការណ៍ដែលបានវិវត្តជាងប៉ុន្មានពីរបីខែនេះនឹងបង្ហាញថាឡេ-ដ្វឺនបានយល់ខុសក្នុងការវាយ តម្លៃរបស់ គាត់ចំពោះនួន-ជា។ខណៈពេលនោះនៅភ្នំពេញពួកមេដឹកនាំកម្ពុជាបានបង្កើនឡើងនូវការភ័យខ្លាចដែលពុះកញ្ជ្រោលឡើងនិងការស្អប់ខ្ពើមចំពោះមេដឹកនាំវៀតណាម ជាលទ្ធផលនៃភាពត្រួតត្រាជាប្រវត្តិសាស្ត្ររបស់វៀត

ណាមលើប្រទេសរបស់ខ្លួន។ ដោយការប្រមើលមើលជាមុនរបស់កម្ពុជាយុទ្ធសាស្ត្រ របស់ វៀតណាមត្រូតត្រាឥណ្ឌូចិនបានពាក់ព័ន្ធនឹងការបញ្ជ្រាបបក្សកុម្មុនិស្តកម្ពុជានិងលាវជាមួយនឹងពួកកម្មាភិបាលដែលអប់រំដោយ វៀតណាម។ ដោយហេតុផលនេះ នៅពេលក្រុមដំបូរនៃបុគ្គលិកខ្មែរក្រហមអបរំដោយវៀតណាម ខាងជើងបានត្រឡប់មកប្រទេសវិញ ពួកគេភ្លាមៗក៏ត្រូវគេធ្វើបន្សុទ្ធកម្មចេញពីបក្ស។ កំឡុងពេល ប៉ុន្មានខែបន្តបន្ទាប់ការបរាជ័យនៃរបបលន់-ណុល ប៉ុល-ពតបានបន្ត ធ្វើ បន្សុទ្ធកម្មបក្សរបស់គាត់និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យក្នុងនោះដែលគាត់បាន ជឿ ថាជា ភ្នាក់ងាររបស់សូវៀតនិងវៀតណាម។ ក្រោយមកទៀតនៅក្នុងបរិបទនៃដោគជ័យនិយមបានអ្នូតអាងដាក់ពួកមេដឹកនាំខ្មែរក្រហមក្នុងសង្គ្រាមដែលពួកគេបានអះអាងថាពួក គេបានកម្ចាត់ ចក្រពត្តិនិយមអាមេរិកដោយកណ្ដាប់ដៃពួកគេតែឯង កម្ពុជាប្រជាធិបតេយ្យបានចាប់ផ្ដើមនាំឱ្យមានសង្គ្រាមប្រឆាំងនឹង វៀតណាម។ពេលនោះដែរកងទ័ពបដិវត្តន៍កម្ពុជាបានធ្វើការត្រៀមទុកសម្រាប់សង្គ្រាមប្រឆាំងនឹងវៀតណាមប្រព័ន្ធផ្សព្វផ្សាយដែលគ្រប់ គ្រងដោយរដ្ឋនៅ វៀតណាមបានបញ្ជូនសារអបអរសាទរដល់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យក្នុងខួបអនុស្សាវរីយលើកទីពីរនៃការ បង្កើតឡើងរបស់របបនេះនៅថ្ងៃ១៧មេសា១៩៧៧។ថ្ងៃ៣០មេសា១៩៧៧ខួបអនុស្សាវរីយលើកទីពីរនៃការធ្លាក់សៃហ្គនកម្ពុជាបានឆ្លើយ តបមកក្នុងទម្រង់ជាការវាយប្រហារយោធាទល់នឹងខេត្តវៀតណាម អាន យ៉ាង (ពាមបារាជ) និង ចូវដុក ដោយសម្លាប់អសេនិកជនយួន រាប់រយនាក់។ កងទ័ពប្រជាជនវៀតណាមបានឆ្លើយតបវិញដោយការរំកិលទ័ពរបស់ខ្លួនទៅ តំបន់ ដែលវាយប្រហារដោយកម្ពុជា និង នៅថ្ងៃ៧មិថុន១៩៧៧ វៀតណាមបានស្នើសុំអោយមានការជជែកជាន់ខ្ពស់ដើម្បីពិភាក្សាបញ្ហានានាដែល មិនទាន់ បានដោះស្រាយ។ ថ្ងៃ១៨មិថុនា ១៩៧៧ រដ្ឋាភិបាលកម្ពុជាបានឆ្លើយតបដោយការទាមទារអោយវៀតណាមដកអង្គភាពទ័ព របស់ខ្លួនទាំងអស់ ចេញពីតំ បន់ជម្លោះ ហើយ បង្កើតតំបន់គ្មានកងទ័ពរវាងកងកម្លាំងប្រឈមគ្នាទាំងពីរ។ទាំងសងខាង មិនបានយកចិត្តទុកដាក់លើសំណើរបស់គ្នា ទៅវិញទៅមកទេ ហើយកងទ័ពបដិវត្តន៍កម្ពុជាបានបន្តបញ្ជូនទាហានឆ្លងកាត់ព្រំដែនដើម្បីវាយប្រហារទីប្រជុំជននិងភូមិយួន។នៅខែ កញ្ញា ១៩៧៧ កងកាំភ្លើងធំកម្ពុជាបានវាយប្រហារភូមិវៀតណាម ជាច្រើនតាមបណ្ដោយព្រំដែន និងភូមិប្រាំមួយនៅខេត្តឌងថាបដែល ត្រូវរុករានដោយទ័ពថ្មើរជើងកម្ពុជា។ រយៈកាលខ្លីក្រោយមក កងពលធំទាំងប្រាំមួយ នៃកង ទ័ពបដិវត្តន៍កម្ពុជាបានរុលមក ប្រហែល ១០ សហាតិមាត្រ (៦,២ ម៉ាយ)រឺ (គីឡូម៉ែត)ចូលទៅក្នុងខេត្តតៃនិញ (រោងដំរី) ដែលជាទីដែលពួកគេបានសម្លាប់ អសេនិកជនយួនច្រើន ជាង១០០០នាក់។ ដោយបានខឹងដោយសារការវាយសម្រុកចូលបន្តបន្ទាប់របស់កម្ពុជា កងទ័ពប្រជាជនវៀតណាម បានប្រមូលផ្ដុំគ្នាប្រាំ បីកងពលធំ ដែលបានប៉ាន់ប្រមាណជិត៦០០០០នាក់ ដើម្បីផ្ដើមការវាយលុកសងសឹកនឹង

កម្ពុជាវិញ។ ថ្ងៃ១៦ធ្នូ១៩៧៧ កងពលធំរបស់ វៀតណាម ដែលមានជំនួយពីធាតុ សំខាន់នៃកងទ័ពអាកាសប្រជាជនវៀតណាម បានឆ្លងកាត់ព្រំដែនតាមរយៈការបណ្តេញចោលជា ច្រើនលើកច្រើនសាដែលមានគោលដៅ ក្នុងការ បង្ខំឱ្យ រដ្ឋាភិបាលកម្ពុជាចរចារ។នៅឯសមរភូមិ ពួកខ្មែរបានខាតបង់លើដីភ្លាមនូវអង្គ ភាពប្រយុទ្ធរបស់ខ្លួនដែលត្រូវបានរុញច្រានឱថយក្រោយវិញដោយពួកយួន។ នៅចុងខែធ្នូ១៩៧៧ វៀតណាមបានទទួល បានជ័យជម្នះ កងទ័ពយ៉ាងជាក់ច្បាស់លើកម្ពុជា ដូចគ្នាដែរក្បួនទ័ពរបស់វៀតណាមបានចល័តឆ្លង កាត់ខេត្ត ស្វាយរៀងនិងត្រឹមតែឈប់រយៈពេលខ្លី ក្នុងការចូលទៅទីរួមខេត្តនេះ។ ទោះបីជាភាពសាហាវនៃការសងសឹករបស់វៀតណាមយ៉ាងណាក៏ដោយ ក៏រដ្ឋាភិបាល កម្ពុជានៅតែរឹង ទទឹងដដែល។ ថ្ងៃ៣១ធ្នូ ១៩៧៧ ខ្មែរ-សំផនបានប្រកាសថារដ្ឋាភិបាលកម្ពុជានឹងផ្តាច់ទំនាក់ទំនងការទូតជាបណ្តោះអាសន្នជាមួយវៀត ណាម ហើយរហូតដល់កងទ័ពវៀតណាមដកចេញពី ទឹកដីពិសិដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ។ថ្ងៃ៦មករា១៩៧៨ កងពលធំវៀតណាម គឺ នៅត្រឹមតែ៣៨ សហាតិមាត្រ (២៤ ម៉ាយ)(គីឡូម៉ែត្រ)ពីភ្នំពេញប៉ុណ្ណោះ តែរដ្ឋាភិបាលវៀតណាមបានសម្រេចចិត្តដកទ័ពរបស់ខ្លួន ពី កម្ពុជាព្រោះពួក គេបានបរាជ័យដើម្បី សម្រេចវត្ថុបំណង នយោបាយរបស់វៀតណាម។ កំឡុងការដកចេញ កងទ័ពវៀតណាមក៏បាន ជម្លៀសពួកអ្នកទោសរាប់ពាន់នាក់និងពួកជនភៀសខ្លួនអសេនិក ដែលរួមមានមេដឹក នាំអនាគតលោកហ៊ុន-សែនផង។

## ១៩៧៨ ការរៀបចំដើម្បីការប្តូររបប

ជំនួសអោយការចេះប្រមាណដោយការបង្ហាញកងកម្លាំងវៀតណាម រដ្ឋាភិបាលកម្ពុជាបានអួតថាការដកទ័ពរបស់វៀតណាម គឺ ជាជ័យជំនះ ដ៏ធំសម្រាប់កម្ពុជា ប្រជាធិបតេយ្យ ដែលប្រៀបធៀបរឿងនេះទៅនឹង ការបរាជ័យនៃចក្រពត្តិនិយមស.រ. នៅថ្ងៃ១៧ មេសា ១៩៧៥។ ពួកខ្មែរបានបន្តបន្ថែមអះអាងថា ជ័យជំនះ៦មករារបស់យើងលើពួកអ្នកទេសនុពន្ធនិយមសត្រូវអ្នកឈ្លានពានយួនបានផ្តល់ ឱ្យ យើងនូវជំនឿចិត្តដ៏ខ្លាំងក្លាជាកម្លាំងដល់ប្រជាជននិងប្រទេសជាតិយើង នៅក្នុងបក្សកុម្មុយនិស្តកម្ពុជាយើង និងកងទ័ពបដិវត្តន៍ របស់ យើងហើយនៅក្នុងជួរបក្សយើងនៃសង្គ្រាមរបស់ប្រជាជន។ពួកមេដឹកនាំកម្ពុជាបានអះអាង ថា ទាហានកម្ពុជាម្នាក់ត្រូវស្មើនឹងទាហាន យួន៣០នាក់ ដូច្នេះបើកម្ពុជាអាចកើនទាហានពីរលាននាក់ពីអត្រាប្រជាជនប្រាំបីលាននាក់ អាចលុបបំបាត់ចោលប្រជា ជនយួន៥០ លាននាក់និងនៅមានប្រជាជនប្រាំមួយលាននាក់ដែលនៅសល់។ ជាការពិត ពួកមេដឹកនាំកម្ពុជាធម្មតាមិនយក ចិត្តទុកដាក់ស្ថានភាព ប្រជាជននៅ ក្នុងប្រទេសរបស់ពួកគេនិងវៀតណាមឡើយ ពួកវៀតណាម ទោះបីជាក្រ

ក៏ពិតមែន ក៏ស្ថានភាពរូបរាងកាយល្អដែរ ដែលគ្រា នោះដែរប្រជាជន កម្ពុជាអស់ ទាំង កម្លាំងកាយនិងចិត្តដោយពលកម្មយ៉ាងលំបាកជាច្រើនឆ្នាំ ការអត់ឃ្លាននិងជំងឺដង្កាត់។

បដិរូបរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានៅឯអតីតការិយាល័យកណ្តាលនៅភ្នំពេញបន្ថែមទៅនឹងភាពខុសគ្នាខាងប្រជាជនក៏មាន ភាពខុសគ្នាធំមួយទៀត រវាងសមត្ថភាពប្រយុទ្ធនៃកងទ័ពនៃប្រទេសទាំងពីរផងដែរ។នៅក្នុងឆ្នាំ១៩៧៧ វៀតណាមត្រូវបានប៉ាន់ប្រមាណ មានទាហាន ៦១៥០០០នាក់និងរថក្រោះ៩០០គ្រឿងដែលបានគាំទ្រដោយកងទ័ពអាកាសសមាជិក១២០០០នាក់ជាមួយយន្តហោះប្រយុទ្ធ ៣០០គ្រឿង រួមមានពួកយន្តហោះទម្លាក់គ្រាប់ បែក ធុន ស្រាលមួយពួក។ ក្នុងការប្រៀបធៀប កម្ពុជាមានកងទ័ព៧០០០០នាក់រថក្រោះ ធន់ធ្ងន់តិចតួចតែប៉ុណ្ណោះ យានយន្តពាសដែក២០០គ្រឿង និងសមត្ថភាពអាកាសមានកំណត់។ ទោះបីជាប្រឈមភាពមិនស្មើគ្នាដ៏ខ្លាំង ដូចនេះក៏ដោយ ក៏កម្ពុជាមិនបានបង្ហាញសញ្ញានូវការស្ទាក់ស្ទើរពេលដូចគ្នានេះដែរ កងទ័ព របស់ ខ្លួនបានបន្តវាយ សម្រុកតំបន់ព្រំ ដែនវៀតណាម។ នៅខែមករា១៩៧៨ កងកម្លាំងកម្ពុជានៅតែកាន់កាប់បានភាគមួយចំនួននៃទឹក ដីវៀតណាមនិងចាប់ ផ្តើមរុករានទី ប្រចាំការខាងក្រៅរបស់វៀតណាមនៅក្នុងខេត្តហាទៀង។ ថ្ងៃ២៧មករា១៩៧៨ វៀតណាមបានចាប់ផ្តើមពីងកងទ័ពកម្ពុជានៅតាម បណ្តោយតំបន់ ព្រំ ដែនឱ្យផ្តួលរំលំរបបខ្មែរក្រហម។

ប្រឈមនឹងពីក្រោយឆាកនៃការប៉ះទង្គិចយោធា រវាងថ្ងៃ៩មករានិង២០កុម្ភៈ១៩៧៨ រដ្ឋមន្ត្រីការបរទេសរងវៀតណាមផាន-ហៀន បាន ធ្វើដំណើរជាច្រើនលើកទៅ ប៉ិជិងដើម្បីធ្វើការពិភាក្សាជាមួយពួកអ្នកតំណាងរដ្ឋាភិបាលកម្ពុជា ដែលនៅទីបំផុតបាន បង្ហាញថាគ្មាន បានផ្លែផ្កាទេ។ ថ្ងៃ១៨មករា១៩៧៨ ចិនបានព្យាយាម សម្រុះសម្រួលការចរចារបន្ថែមរវាងកម្ពុជានិងវៀតណាមដែលនៅពេល នោះ អនុរដ្ឋមន្ត្រីប្រមុខតឹង-យិងឆវ៍បានធ្វើដំណើរទៅភ្នំពេញ ដែលលោកស្រីត្រូវជួបជា មួយការតទល់យ៉ាងខ្លាំងដោយពួកមេដឹកនាំកម្ពុជា។ ខណ:ពេលនោះ ពួកអ្នករដ្ឋការរដ្ឋាភិបាលវៀតណាមបានផ្តើមប្រព្រឹត្តិជំនួបសម្ងាត់ជាមួយសោ-ភឹម ពួកមេ ដឹកនាំខ្មែរក្រហម នៅភូមិ ភាគយោធាបូព៌ារបស់កម្ពុជា ដើម្បីធ្វើផែនការការបះបោរយោធាដែលនៅពីក្រោយខ្នងដោយវៀតណាម។ កំឡុងសម័យដដែលនោះ ដំណើរត្រឡប់ក្រោយនានារបស់យោធាដែលមានបទពិសោធន៍ដោយកងទ័ពបដិវត្តន៍កម្ពុជានៅក្នុងភូមិភាគយោធាបូព៌ាបានក្រើនរំ លឹកប៉ុល-ពតអោយ ចាត់ តំបន់នេះជាសំបុកនៃពួកក្បត់។

ដើម្បីបន្សុទ្ធភូមិភាគយោធាបូព៌ាទាំងនោះ គាត់បានដឹងថាត្រូវបានធ្វើឱ្យល្អក់កករដោយពួកវៀតណាម ប៉ុល-ពតបានបញ្ជាអង្គភាព យោធានានាមក ពីភូមិភាគ និរតីផ្លាស់ទៅកាន់ខាង

កើតកម្ពុជានិងកម្ចាត់ចោលពួកក្បត់ដែលលាក់ខ្លួន។ ដោយមិនស៊ូទ្រាំនឹងការវាយ ប្រហារពីរដ្ឋាភិបាលកម្ពុជា សោ-ភឹមក៏បានសម្លាប់ ខ្លួន ដែលកាលណោះឧបរបស់គាត់លោកហេង-សំរិនបានរត់ទៅវៀតណាម។ ថ្ងៃ ១២មេសា១៩៧៨ រដ្ឋាភិបាលកម្ពុជាបានប្រកាសខ្លួននិង វៀតណាមអាចចរចារ ម្តង ទៀតបានបើសិនជាវៀតណាមបោះបង់ ចោល មហិច្ឆតាវាតទីនិយមរបស់ខ្លួនហើយនិងទទួលស្គាល់អធិបតេយ្យភាពរបស់កម្ពុជា។ យ៉ាងណាមិញ ក៏មានការស្នើ លក្ខខណ្ឌ មុនៗ មួយដែលវៀតណាមសន្យាកិច្ចសន្យាជាច្រើនតាមរយៈបទឈប់បាញ់សាកល្បងរយៈពេលប្រាំពីរខែ។ រដ្ឋាភិបាលវៀតណាមភ្លាមៗ បានបដិសេធ ការទាមទារនេះ ហើយ ជាការឆ្លើយតបវិញ កងពលធំកម្ពុជាពីរកងបានទម្លុះរហូតដល់២ សហាតិមាត្រ (១,២ ម៉ាយ) ចូលទៅក្នុងទឹកដីវៀតណាម និងបានសម្លាប់ រង្គាលអសេនិកជនវៀតណាមជាង៣០០០នាក់ក្នុងភូមិបាជូកនៅខេត្តអានយ៉ាង (មាត់ ជ្រូក)។

លលាដ៍ក្បាលជនរងគ្រោះនៃការសម្លាប់រង្គាលបាជូក។នៅខែមិថុនា១៩៧៨ កងទ័ពអាកាសវៀតណាមបានចាប់ ផ្តើមទម្លាក់គ្រាប់ បែកទីតាំងជាច្រើនរបស់កម្ពុជា តាមបណ្តោយតំបន់ព្រំដែនដែលហោះប្រហែលប្រតិបត្តិការទម្លាក់គ្រាប់បែក៣០ជើងក្នុងមួយថ្ងៃ និងបណ្តាលឱ្យមានសហេតុភាពដ៏ធ្ងន់ធ្ងរលើប្រជាជនខ្មែរ។ តាមដំណាក់កាលក្នុងការប៉ះទង្គិចនោះ ពួកមេដឹកនាំដែលនៅរស់ ភាគ ច្រើន នៅភូមិភាគឃោធាបូព៌ាបានរត់គេចខ្លួនចូលទៅវៀតណាម ជាទីដែលពួកគេបាន ប្រមូលគ្នីគ្នាក្នុងជំរុំសំងាត់ផ្សេងជា មួយនិង គោលបំណងនៃការបង្កើតកងទ័ពរំដោះដែលមានវៀតណាមនៅពីក្រោយខ្នងដើម្បីប្រយុទ្ធប្រឆាំងនឹងរបបខ្មែរក្រហមរបស់ប៉ុល-ពត។ ខណៈពេលនោះដែរនយោបាយការិយាល័យបក្សកុម្មុយនិស្តវៀតណាមកំពុងតែប្រជុំនៅហាណូយ ដើម្បីពិភាក្សា យុទ្ធសាស្ត្ររបស់ខ្លួន សម្រាប់កម្ពុជា។ វាបានសន្និដ្ឋានថារបបខ្មែរក្រហមគឺជាតំណាងនៃចិន ដែលកំពុងព្យាយាមបំពេញសុញ្ញកាសអំណាច ដែលបន្តបន្ទាប់ ពីការដក ទ័ពរបស់សហរដ្ឋ។ ដូចគ្នាដែរ ចិនបានបង្ហាញខ្លួនថាជាសត្រូវធំរបស់វៀតណាម និងរបបពឹងពាក់នៅភ្នំពេញបាន ត្រូវជម្រះ ចោលដោយកម្លាំងយោធាតាមការសន្មត ពីព្រោះតែការ យកលំនាំតាមរបស់វៀតណាមអំពីលទ្ធិសង្គ្រាមប្រជាជនម៉ៅនិយម ដែលមិន បានជោគជ័យទល់នឹងរចនាសម្ព័ន្ធសន្តិសុខរបស់ខ្មែរក្រហម។

ដើម្បីឆ្លុះបញ្ចាំងនូវពួកមេដឹកនាំប្រទេសនេះ ប្រព័ន្ធផ្សព្វផ្សាយដែលគ្រប់គ្រងដោយរដ្ឋរបស់វៀតណាមបានពន្លឿន សង្គ្រាមឃោ សនាប្រឆាំងនឹងពួកខ្មែរក្រហម ដែលមានសារព័ត៌មានញុីនជីនកុម្មុយនិស្តរបស់វៀតណាមដែលស្រែកហៅរកអន្តរាគមន៍ ជារឿយៗ ដើម្បីជួយសង្គ្រោះប្រជាជនកម្ពុជាពីភេរវកម្មក្នុងស្រុកដើមផ្តើម ដោយរបបខ្មែរក្រហម។ បន្ថែមទៀតជំនួសឱ្យការ

បញ្ជូនសាររអបអរសា ទរ ដូចដែលពួកខ្លួនបានធ្វើប៉ុន្មានឆ្នាំមុន ប្រព័ន្ធផ្សព្វផ្សាយវៀតណាម បានផ្លាស់ប្តូរសម្លេង និងបានចាប់ផ្តោមចាត់ទុកថារដ្ឋាភិបាល កម្ពុជាដូចជាបនរបស់ប៉ុល-ពត អៀង-សារីក៏ដូចជាកងទ័ពកម្ពុជាបានបន្តយុទ្ធនាការរបស់ខ្លួននៅវៀតណាម។ នៅជិតចុងខែមិថុនាកង ទ័ពវៀតណាមបានប្រមូលផ្តុំគ្នា ជាកម្លាំងការងារជាច្រើនកងពលធំដើម្បីផ្តើមយុទ្ធនាការ ដែលមានគោលដៅកំណត់ច្បាស់មួយទៀតប្រ ឆាំងនឹងពួកខ្មែរ។ ម្តងនេះ ពួកវៀតណាមបាន រុញច្រើនកងកម្លាំងរបស់កម្ពុជាត្រឡប់ទៅកាន់ទីក្រុងខេត្ត ស្វាយ និងព្រៃវែងហើយ ក្រោយ មកទៀតក៏បាន ដក ថយទៅវិញ។យ៉ាងណាមិញ ដូចដែលពួកគេបានធ្វើពីមុន កងទ័ពកម្ពុជាបាន ចល័តកងកាំភ្លើងធំរបស់ខ្លួនឆ្ពោះទៅ កាន់ព្រំដែននិងបានបន្តបន្តក់ ភូមិនានា របស់ វៀតណាម ហាក់បីដូចជាគ្មានអ្វីកើតឡើងទាល់តែសោះ។

អំឡុងពាក់កណ្តាលទីពីរនៃឆ្នាំ១៩៧៨ ពួកមេដឹកនាំវៀតណាមបានលះបង់ថាមពលរបស់ខ្លួន ជាច្រើនចំពោះយុទ្ធនាការយោធា ប្រឆាំង នឹងរបបខ្មែរក្រហម ដោយ ការស្វែងរកជំនួយ នយោបាយមកពីសហភាពសូវៀត។ ដោយការសង្ខេបខ្លីជាមួយ ពួកអ្នករដ្ឋការក្រសួងការ បរទេស របស់វៀតនាមនៅថ្ងៃ២៥កក្កដា១៩៧៨ ភារធារីសូវៀតនៅហាណូយត្រូវបានគេប្រាប់ ថារដ្ឋាភិបាលកម្ពុជាបានពង្រាយ១៤ ក្នុង ចំណោមកងពលធំទ័ព១៧កងជាទ្បេងទាត់ និងកងវរសេនា ធំតំបន់ ១៦ កងតាមបណ្តោយព្រំដែនជាមួយវៀតណាម។ ក្រោយមកទៀត នៅដើមខែ កញ្ញា១៩៧៨ ឡេ-ដ្វឹនបានផ្តល់ដំណឹងដល់ឯកអគ្គរដ្ឋ ទូតសូវៀតថាវៀតណាម មាន បំណងដោះស្រាយបញ្ហា ចោទទាំងនេះ ទាំងស្រុងអំពីកម្ពុជានៅដើមឆ្នាំ១៩៧៩។កាលណោះវៀតណាម កំពុងតែដាក់មូលដ្ឋាន នយោបាយសម្រាប់យុទ្ធនាការប្រឆាំងនឹងកម្ពុជា នាវាសូវៀតត្រូវបាន រាយការណ៍មិនត្រូវបានផ្ទុកអាវុធធន់ធ្ងន់និងយុទ្ធភណ្ឌយោធានៅឆកសមុទ្រខាមរ៉ាញទេ។ នៅ ខែតុលា១៩៧៨ វិទ្យុ វៀត ណាមបានផ្សព្វផ្សាយអ្វីដែលពួកគេបានអះអាងថាមានករណីជាច្រើននៃការបះបោរប្រឆាំងរបបខ្មែរក្រហម ដែលកំពុង ជម្រុញ កងទ័ពកម្ពុជាផ្តួលរំលំបនប៉ុល-ពត អៀង-សារីរីក៏បានរត់ទៅវៀតណាម។

នៅក្នុងចំណុចប្រែប្រួលដ៏សំខាន់មួយក្នុងការប្រណាំងគ្នានៃទំនាក់ទំនងការទូតសូវៀត-វៀតណាម និងចិន-វៀតណាម និងនៅទីបំ ផុតគឺជា ការលុកលុយរបស់វៀតណាមនៅកម្ពុជានៅថ្ងៃ៣វិច្ឆិកា១៩៧៨សន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការមួយត្រូវបានចុះហត្ថ លេខា រវាងវៀតណាមនិងសហភាពសូវៀតដែល ធានា នូវដំណែលនៃជំនួយយោធាសូវៀតសំខាន់ៗក្នុងឈុតឆាក(សេណារីយ៉ូ)ថាចិន បានអន្តរាគមក្នុងការប៉ះទង្គិចគ្នានេះ។ ក្រោយមក នៅខែវិច្ឆិកា១៩៧៨ បញ្ជាការ មួយនិងទីបញ្ជាការត្រួតពិនិត្យត្រូវបាន បង្កើតឡើង សម្រាប់ការលុកលុយកម្ពុជាដែល

បានរៀបចំផែនការហើយ ដែលមានឧត្តមសេនីយ៍ថ្នាក់ទីមួយ (ទេសឧត្តម សេនីយ៍) ឡេ-ឌឹក អា ញ ទទួលបន្ទុកគ្រប់គ្រងពេញទីនៃអង្គភាពយោធាវៀតណាមតាមបណ្តោយតំបន់ព្រំដែន។ រដ្ឋាភិបាលវៀតណាម ដើម្បីជំនួសឱ្យការខាត បង់ ដំបូងៗនិងបានបង្កើនអង្គភាពរបស់ខ្លួនតាមបណ្តោយព្រំដែន ដែលកែនបាន៣៥០០០នាក់ចូលទៅក្នុងកងទ័ព។ កាលណោះដែរ ពួកទ័ពដែល កែនថ្មីៗ កំពុង តែបំពេញការហ្វឹកហាត់ កងពលធំ១០កងត្រូវបានពង្រាយដាក់តំបន់ព្រំដែន ឡុងអាន(គោះគង) ឌងថាប និងខេត្តតៃនិញ (រោងដំរី)។ វៀតណាមក៏បានផ្លាស់ប្តូរ កងពលធំបីកងដែលឈរជើងនៅភាគខាងត្បូងលាវទៅកាន់ព្រំដែនលាវ-កម្ពុជា។ ថ្ងៃ១៣ធ្នូ១៩៧៨ រដ្ឋាភិបាលចិនបានព្រមានវៀតណាម ថាការអត់ធ្មត់ របស់ខ្លួន មានកំណត់ និងថាវៀតណាមនឹង ត្រូវបានដាក់ ទណ្ឌ កម្ម បើសិនជាខ្លួនប្រកាន់អាកប្បកិរិយា *ជិះសេះលែងដៃ*(របៀបអត់បង្ហៀរ) ដូច្នេះ។

មិនតិចទេចំណិតចុងក្រោយនៃយុទ្ធសាស្ត្ររបស់វៀតណាមបានលេចឡើងនៅពេលដែលវៀតណាមបានប្រកាសការបង្កើតឡើង នៃរណសិរ្សសាមគ្គីសង្គ្រោះជាតិ កម្ពុជា (រ.ស.ស.ជ.ក.) ក្នុង *តំបន់រំដោះ*នៃកម្ពុជា។ ហាណូយបានអះអាងរ.ស.ស.ជ.ក.គឺជាចលនា កុម្មុយនិស្ត កម្ពុជាឯករាជ្យមួយដែលមាន សមាជិក ដកចេញ ពី គ្រប់វិជ្ជាជីវៈ។ លោកហេង-សំរិន ដើមឡើយជាសមាជិកមួយ រូបនៃ ពួកខ្មែរក្រហមនិងមេបញ្ជាការនៃកងពលធំទី៤កម្ពុជា ជាប្រធាននៃគណៈកម្មាការមជ្ឈិម នៃ រ.ស.ស.ជ.ក.។កាលពីមុន រ.ស.ស.ជ.ក. ត្រូវបានគេស្គាល់ថាជារដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ននៃកម្ពុជា (រ.ប.ប.ក.) ដែលរួមផ្សំដោយអតីតពួកកម្មាភិបាល ខ្មែរក្រហម ៣០០នាក់ដែលបានរត់ទៅវៀតណាម។ រ.ស.ស.ជ.ក.ជារឿយៗបានបញ្ជូនពួកអ្នកតំណាងទៅក្រៅ ប្រទេសក្នុងការស្វែងរកជំនួយ មុនពេល វៀត ណាមបានបោះបង់ចោលគំនិត 'សង្គ្រាមប្រជាជន' ដោយអនុគ្រោះដល់យុទ្ធនាការយោធាអនុសញ្ញា ស្រដៀងទៅ នឹងការលុក លុយរបស់សូវៀត នៅឆែកកូស្លូវ៉ាគីនៅឆ្នាំ១៩៦៨។

មិនបានធ្វើល្អប្រសើរជាងដោយការចម្រើនខាងយោធារបស់វៀតណាមរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យរស់តែពង្រឹងកងទ័ពរបស់ ខ្លួនជាមួយជំនួយរបស់ចិន។ នៅប៉ុន្មានឆ្នាំមុនៗ ចិនបានត្រឹមតែផ្តល់ឱ្យកងទ័ពបដិវត្តន៍កម្ពុជា ជាមួយចំនួននៃសព្វាវុធនិងយុទ្ធ ភណ្ឌ មានកំណត់ ក៏ប៉ុន្តែពេលដែលទំនាក់ទំនង ជាមួយវៀត ណាមបានកាន់តែអាក្រក់នៅឆ្នាំ១៩៧៨ ប៉ិជិងបានបង្កើតផ្លូវផ្គត់ផ្គង់បន្ថែមឆ្លង ទៅកម្ពុជានិងបានបង្កើនចំណុះនៃអាវុធយោធាធុនធ្ងន់ ដែលបានធ្វើដំណើរចុះ មក តាមផ្លូវនីមួយៗ។ នៅមុនថ្ងៃនៃការលុកលុយរបស់ វៀតណាម កម្ពុជាមានទាហាន៧៣០០០ដែលបានប៉ាន់ស្មានក្នុងភូមិភាគយោធាបូព៌ាដែល នៅជាប់ព្រំដែនវៀតណា

ម។ នៅពេលនោះ គ្រប់សាខាទាំងអស់នៃកងទ័ពកម្ពុជាបានពង្រឹងគួរអោយកត់សម្គាល់ដោយចំនួនដ៏ច្រើននៃគ្រឿងបរិក្ខាយោធាដែលផលិតនៅចិន ដែល រួមមានយន្តហោះប្រដេញ ទូកល្បាត កាំភ្លើងធំធុនធ្ងន់ កាំភ្លើងប្រឆាំងយន្តហោះ រថដឹកនិងរថក្រោះជាច្រើន។ ជាការបន្ថែមមាន ពួកទី ប្រឹក្សា ចិនរវាង ១០០០០នាក់និង២០០០០នាក់ដែលមានសមត្ថភាពខាងយោធានិងអសេនិក ដែលផ្តល់ការគាំទ្ររបស់ខ្លួនដល់ របប ខ្មែរក្រហម។

- ការលុកលុយកម្ពុជា

ដើមឡើយនៅខែធ្នូ១៩៧៨ កម្លាំងដែលបង្កើតថ្មីរបស់កម្ពុជាត្រូវបានសាកល្បងនៅពេលដែលមានការវាយលុកមួយរបស់វៀតណាម ដែលមានកងពលធំពីរ បាន ឆ្លងកាត់ព្រំដែននិងរំកិលទៅទីប្រជុំជនក្រចេះ គ្រានោះកងពលធំគាំទ្រផ្សេងៗទៀតត្រូវបានដាក់ពង្រាយ តាមបណ្តោយផ្លូវក្នុងតំបន់ ដើម្បីកាត់ផ្តាច់ កន្ទុយដឹក ជញ្ជូននៃអង្គភាពទ័ពរបស់កម្ពុជា។ ទោះបីជាកំពុងតែរីករាយនឹងជំនួយសប្បុរស ពីចិនក៏ពិតមែន ក៏កងទ័ពកម្ពុជា មិនអាចស៊ូទ្រាំ នឹងការវាយលុករបស់ វៀតណាម បានឡើយ និងបានរងគ្រោះដោយសហេតុភាពដ៏ ធ្ងន់ធ្ងរ។ នៅទីបញ្ចប់ ថ្ងៃ ២៥ធ្នូ១៩៧៨ វៀតណាមបានផ្តើមការលុកលុយពេញទីដោយប្រើកងពលធំ១៣កង មានប្រមាណទាហាន ១៥០០០០នាក់ដែលបានគាំទ្រយ៉ាងល្អដោយកាំភ្លើងធំធុនធ្ងន់និងកម្លាំងអាកាស។ គ្រាដំបូង កម្ពុជាបានប្រជែង ដោយផ្ទាល់នឹងកង ទ័ព វៀតណាមប្រហែលជាតាមរយៈវិធីប្រយុទ្ធគ្នាតាមអនុសញ្ញាប៉ុន្តែកលយុទ្ធនេះបានហុចជាលទ្ធផលក្នុងការខាតបង់ពាក់កណ្តាលនៃកង ទ័ពបដិវត្តន៍ កម្ពុជា ក្នុង រយៈពេលពីរអាទិត្យ ។ បរាជ័យយ៉ាងធ្ងន់ធ្ងរលើសមរភូមិបានក្រើនរំលឹកឱ្យពួកមេដឹកនាំកម្ពុជាជាច្រើនជម្លៀស ខ្លួនទៅកានតំបន់ភាគខាងលិចនៃប្រទេសនេះ។ ថ្ងៃ ៧មករា១៩៧៩ កងទ័ពវៀតណាមបានចូលភ្នំពេញរួមជាមួយពួកសមាជិក នៃ រ.ស. ស.ជ.ក.។ នៅថ្ងៃបន្ទាប់ រដ្ឋកម្ពុជានិយមវៀតណាម ដែលគេ ស្គាល់ថា ជា សាធារណរដ្ឋប្រជាមានិតកម្ពុជា (ស.ប.ក.) ត្រូវបានបង្កើត ឡើង ដែលមានលោកហេង-សំរិនជាប្រធានរដ្ឋនិងលោកប៉ែន-សុវណ្ណ ជាលេខា (អគ្គលេខាធិការ) នៃ បក្សបដិវត្តន៍ប្រជាជនកម្ពុជា។

ពួកមេដឹកនាំខ្មែរក្រហម ដែលមានរចនាសម្ព័ន្ធនយោបាយនិងកងទ័ពជាច្រើនបានបែកខ្ញាត់ខ្ញាយគ្នាដោយការ លុកលុយ របស់វៀត ណាម ត្រូវបង្ខំឱ្យជ្រកកោននៅ ប្រទេសថៃជាទីដែលមានការស្វាគមន៍យ៉ាងកក់ក្តៅដោយរដ្ឋាភិបាលថៃ។ ទោះពីជាមានការប្រជែងខាង សេដ្ឋកិច្ចដ៏លើសលុប បាននាំមកដោយពួក ខ្មែរក្រហម និង ពួកជនភៀសខ្លួនដែលមកតាម ក៏រដ្ឋាភិបាលថៃបានផ្តល់ជម្រកនិងការពារ ពួកខ្មែរក្រហមនៅឯជំរុំខាវឡាននៅខេត្តត្រាត។ ខណៈពេលនោះដែរ នៅភ្នំពេញ របបកម្ពុជាថ្មីបានព្យាយាមកសាងនូវជីវភាពសេដ្ឋកិច្ច និងសង្គមនៃ

ប្រទេសឡើងវិញ ដែលត្រូវបានខ្ទេចខ្ទីយ៉ាងច្រើនអស់ច្រើនទសវត្សនៃការ ចលាចលនយោបាយ និងសង្គ្រាមឥតឈប់ឈរ។ យ៉ាងណាមិញ កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជាថ្មីដើម្បីកសាងប្រទេសនេះឡើងវិញ ត្រូវរំខានយ៉ាង ខ្លាំងដោយ កង្វះ បុគ្គលិកដែល ចេះដឹងនិងមានគុណវឌ្ឍ ដូចគ្នាដែរភាគច្រើននៃប្រជាជនដែលចេះដឹងបានរត់គេចចេញពីប្រទេសរឺក៏ត្រូវសម្លាប់ដោយរបបខ្មែរក្រហម កំឡុង ប៉ុន្មាន បួនឆ្នាំមុន។ នៅចុងឆ្នាំនោះ ការព្យាយាមរបស់របបថ្មីនៅក្នុងការកសាងជាតិត្រូវបានប្រឈមគ្នាបន្ថែមទៀតដោយ ពួក ក្រុមតស៊ូប្រឆាំងវៀតណាមដែលកំពុងប្រតិបត្តិការតាមតំបន់ភាគខាងលិចនៃប្រទេសនេះ។

- ***ការឆ្លើយតបពីសហគមន៍អន្តរជាតិ***

*រយៈពេលដ៏ខ្លី បន្ទាប់ពីការធ្លាក់ភ្នំពេញទៅឱ្យកងកម្លាំងវៀតណាមនិងសម្ព័ន្ធមិត្តកម្ពុជារបស់ពួកគេ នៅខែមករា១៩៧៩ ពួកអ្នកតំ ណាង នៃកម្ពុជា ប្រជាធិបតេយ្យ បានដង្ហើយហៅឱ្យមានជំនួបជាបន្ទាន់នៃក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ ដូច្នេះសម្តេចនរោត្តម-សីហនុអាចបង្ហាញករណីរបបដែលបានដួលរលំនេះ។ ទោះ បីជាមានការជំទាស់ដ៏ខ្លាំងពីសហភាពសូវៀតនិងឆែកកូស្លាវ៉ាគីក៏ដោយ ក៏ក្រុមប្រឹក្សាសន្តិសុខស.ប.បានផ្តល់ឱកាសនេះដល់ព្រះសីហនុដែរ។ថ្វីត្បិតព្រះ សីហនុ ខ្លួនព្រះអង្គបាននៅឃ្លាតឆ្ងាយពីការរំលោភ បំពានសិទ្ធិមនុស្សរបស់ខ្មែរក្រហម ក៏ទ្រង់បានចោទប្រកាន់វៀតណាមថាកំពុងតែប្រើការឈ្លានពានដើម្បីរំលោភ បំពានអធិបតេយ្យភាពរបស់កម្ពុជា។ ដូចគ្នានេះដែរ ទ្រង់បានទាមទារឱ្យប្រទេសក្នុងស.ប.ទាំងអស់បញ្ឈប់ជំនួយជាបណ្តោះអាសន្ន ទៅវៀតណាម និងមិន ទទួល ស្គាល់របបដែលបង្កើតឡើងដោយវៀតណាមមួយនេះទេ។ ជាលទ្ធផល សមាជិកមិនចូលបក្សសម្ព័ន្ធនៃក្រុមប្រឹក្សាសន្តិសុខស.ប .បានស្នើការដោះស្រាយ ដែល ព្រាងទុកសុំឱ្យមានបទឈប់បាញ់ និងការដកកងកម្លាំងបរទេសចេញពីកម្ពុជាដែលត្រូវបានយល់ព្រម ដោយចិន បារាំង ន័រវែស ព័រទុយហ្គាល់ សហរដ្ឋ និងសហ រាជាណាចក្រ (រាជាណាចក្ររួម)។ យ៉ាងណាក៏ដោយ ដំណោះស្រាយនេះមិន ត្រូវបានយល់ព្រមដោយសារតែការប្រឆាំងយ៉ាងខ្លាំង ពីសហភាពសូវៀត និង ឆែកកូស្លាវ៉ាគី។*

*នៅចន្លោះ១៦-១៩កុម្ភៈ១៩៧៩ វៀតណាមនិងរបបកម្ពុជាថ្មីបានធ្វើជំនួបកំពូលដែលសម្រេចបានជាមួយការចុះហត្ថលេខាប្រទេស ទាំង ពីរ នូវសន្ធិសញ្ញាសន្តិភាព មិត្តភាពនិងសហប្រតិបត្តិការ។មាត្រា២នៃសន្ធិសញ្ញាបានចែងថាសន្តិសុខ វៀតណាមនិងកម្ពុជាត្រូវ ទាក់ទងរវាងគ្នា ដូច្នេះប្រទេសទាំងពីរនឹងជួយ ការពារគ្នា ទៅ វិញទៅមក ប្រឆាំងនឹងផែនការណ៍និងទង្វើនៃអន្តការដោយកម្លាំង ចក្រ ពត្តិ និយមនិងកម្លាំងប្រតិកម្មអន្តរជាតិដោយហេតុនោះកំពុង តែធ្វើឱ្យស្របច្បាប់ នូវ វត្តមាននៃកងទ័ពវៀតណាមនៅលើដីកម្ពុជា។ ឆាប់ៗបន្ទាប់មក សហភាពសូវៀ*

ត ប្រទេសសង្គមនិយមនានានៅអឺរ៉ុបខាងកើត និងឥណ្ឌា បានទទួលស្គាល់ ភ្លាមៗនូវសាធារណរដ្ឋ ប្រជាមានិតកម្ពុជាដែលបន្តុបដោយវៀតណាម។ រដ្ឋាភិបាលសូវៀតបានសរសើរជ័យជំនះគួរអោយកត់សម្គាល់របស់ស.ប.ក.និងបាន បង្ហាញនូវការគាំទ្ររបស់ខ្លួនពេញទីដល់ការរីកចម្រើនរបស់របបនេះឆ្ពោះទៅកាន់សង្គមនិយម។ បន្ថែមទៀត ពួកសូវៀតបានរិះគន់ យ៉ាងខ្លាំងក្លាដល់កំណត់ត្រា ភេរវកម្មរបស់របបខ្មែរក្រហម ដែលពួកគេបាននិយាយបញ្ជាក់គឺត្រូវបានបង្គាប់បញ្ជាដោយចិន។

នៅក្នុងសម័យប្រជុំនៃមហាសន្និបាតស.ប.ទី៣៤ ពួកអ្នកតំណាងនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យ ទាំងពីរបានអះអាង សិទ្ធិដើម្បី តំណាងឱ្យប្រទេសរបស់ពួកគេ។ ពួកអ្នកតំណាងទាំងពីរមុននេះក៏បានប្រាប់ដល់ប្រជាជាតិសមាជិកនៃ ក្រុមប្រឹក្សា សន្តិសុខស.ប.ថាខ្លួនជាអ្នកតំណាង ស្រប ច្បាប់តែមួយនៃកម្ពុជានិងប្រជាជននៃប្រទេសនេះ។ ជាការឆ្លើយតប គណៈកម្មា ធិការរបស់សារតាំងនៃស.ប.បានសម្រេចចិត្តទទួលស្គាល់កម្ពុជាប្រជាធិបតេយ្យ ដោយសម្លេងប្រាំមួយទល់នឹងបី ទោះបីជាមាន កំណ ត្រាបង្ហូរឈាមរបស់ខ្មែរក្រហមពេលដែលនៅកាន់អំណាចក៏ដោយ។ តាមអនុលោមន៍ ពួកអ្នកតំណាង នៃ កម្ពុជាប្រជាធិបតេយ្យត្រូវ បានអនុញ្ញាតឱ្យមានអាសនៈក្នុងមហាសន្និបាត ដែលមានការគាំទ្រយ៉ាងខ្លាំងពីចិន។ នៅខែមករា១៩៨០ ប្រទេសទាំង២៩បានបង្កើត ទំនាក់ទំនងទូតជាសាធារណរដ្ឋប្រជាមានិតកម្ពុជា នៅឡើយតែជាង៨០ប្រទេសទៀតនៅតែទទួលស្គាល់ភាព ស្របច្បាប់ នៃកម្ពុជាប្រ ជាធិបតេយ្យដែលបាន ដួល រលំហើយ។ នៅក្នុងពេលដូចគ្នានេះដែរ ពួកមហាអំណាចលោកខាងលិចនិងប្រទេសជាសមាជិកនៃសមា គមប្រជាជាតិអាស៊ីអាគ្នេយ៍(ស.ប.អ.អ. រឺ អាស៊ាន) ក៏ បានបញ្ចេញនូវការបន្ទោសយ៉ាងខ្លាំងចំពោះការប្រើប្រាស់កម្លាំងទ័ពរបស់ វៀតណាមដើម្បីដករបបខ្មែរក្រហមចេញ។

ប្រទេសថៃ ដែលមានព្រំដែនរួម៨០០ សហាតិមាត្រ (៥០០ ម៉ាយ)ជាមួយកម្ពុជានិងបានធ្វើឱ្យភ័យខ្លាចជាប្រវត្តិសា ស្ត្រ នូវការវាត ទី និយមរបស់វៀតណាម បាន ទាមទារថាវៀតណាមត្រូវដកទ័ពរបស់ខ្លួនភ្លាមៗពីកម្ពុជាដូច្នេះប្រជាជនកម្ពុជាអាចជ្រើសរើសរដ្ឋាភិបាល មួយដោយសេរីក្រៅពីអន្តរាគមន៍របស់បរទេស។ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ភ្វីលីពីន និងសិង្ហបុរីបានបង្ហាញនូវការគាំទ្ររបស់ខ្លួនចំពោះ ជំ ហររបស់ថៃ។ បន្ថែមទៀត អាស៊ានបានមើលឃើញការលុកលុយនិងការកាន់កាប់បន្តបន្ទាប់របស់វៀតណាមនៅកម្ពុជា ដែលទទួល បានការគាំទ្រយ៉ាងខ្លាំងដោយសូវៀត ជាការគំរាមកំហែង ដែលនាំឱ្យរំខានដល់ សន្តិសុខនិង ស្ថេរភាពក្នុងតំបន់នេះ។ទិដ្ឋភាពនោះត្រូវ បាន រួមចំណែកដោយចិន ដែលបាននបន្តដរាបណានៅតែមានការចោទប្រកាន់វៀតណា

មពីការបង្ខំកម្ពុជាឱ្យចូលទៅក្នុងសហព័ន្ធ ឥណ្ឌូចិន ដើម្បីបម្រើជាទីប្រចាំការក្រៅមួយនៃអនុត្តរភាពពាសពេញពិភពលោករបស់សូវៀត។ សហរដ្ឋ ដែលមិនដែលបា ថៃរក្សា ទម្រង់នៃចំណងការ ទូតណា មួយជាមួយកម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហម បានបង្ហាញឱ្យឃើញនូវការគាំទ្រជា ខ្លាំងចំពោះសមា ជិកភាពនៃអតីតសត្រូវ របស់ខ្លួននៅក្នុង មហា សន្និបាត ស.ប. និងបានបំពងការដង្ហើយហៅរបស់អាស៊ានដើម្បីឱ្យមានការដក កង កម្លាំងកងទ័ពវៀតណាមភ្លាមចេញពីកម្ពុជា។

- ## ចិនលុកលុយវៀតណាម

### អត្ថបទដើមចម្បង: សង្គ្រាមចិន-វៀតណាម

នៅខែកុម្ភៈ១៩៧៩ ចិនបានធ្វើការសងសឹងវិញនឹងការលុកលុយរបស់វៀតណាមនៅកម្ពុជាដោយការបញ្ជូនកងទ័ពជាប្រញាប់មក តាមបណ្ដោយព្រំដែនចិន-វៀតណាម ហើយក្នុងរយៈពេលដប់ថ្ងៃបានទៅដល់ទីរួមខេត្តនានា។ ការប្រយុទ្ធបានជាប់គាំង ដោយសារតែ ផ្លូវខ្វាត់ខ្វែងនៃឧម្មង្គដែលពួកចិនបានជួបប្រទះ មិន ថ្វីទេ កងទ័ពចិនបានកាន់កាប់បានខោបាងនៅថ្ងៃ២ មីនា និងឡាងសឺន នៅថ្ងៃ៤ មីនា តាមរបាយការណ៍នឹងធ្វើដំណើរឆ្ពោះទៅកាន់ហាណូយនៅក្នុងល្បឿងយ៉ាង លឿន ទោះបីជាមិនមានលក្ខខណ្ឌល្អជាមួយខ្សែផ្គត់ ផ្គង់របស់ខ្លួនក៏ដោយ។ ថ្ងៃបន្ទាប់ យ៉ាងណាក៏ដោយ របបក្រុងប៉ិជិងបានប្រកាសថាខ្លួនឹងមិនរំកិល ចូលវៀតណាមកាន់តែជ្រៅទេដោយ លេចឡើងបន្ទាប់ពីការជួបប្រទះនឹងការតស៊ូដ៏សាហាវនិងខ្លាំងក្លាដែលមិនអាចរំពឹងទុកដោយសារកងកម្លាំង វៀតណាម ហ្វឹកហាត់ បានល្អនិងមានបទពិសោធន៍ ដែលបានផ្គត់ផ្គង់ដោយបច្ចេកវិទ្យាអាមេរិកដែលបានបន្សល់ទុកក្រោយពីសង្គ្រាមវៀតណាម។ ដោយមានទំនុកចិត្តថាការ គំរាមកំ ហែងនៃការលុកលុយគឺជាជោគជ័យមួយហើយ ពួកចិនបានដកទ័ពថយ ដែលបន្សល់ទុកនូវ ផ្លូវដានមួយ នៃវិនាសកម្មដែលលាតសន្ធឹង៥០០ សហាតិមាត្រ (៣១០ ម៉ាយ)ជាស្លាកស្នាមរបស់ខ្លួន។ រួមជាមួយជំនួយរបស់ចិន បានបាត់បងបន្ទាប់ ពីសរុបកម្មវិញរបស់វៀតណាម កម្ពុជាត្រូវទុកឱ្យនៅផ្គត់ផ្គង់ខ្លួនឯង។ ទោះពី ជាការបាត់បង់ទាំងស្រុងរបស់ចិនត្រូវបានគេប៉ាន់ ប្រមាណ ខ្ពស់ជាងការបាត់បង់របស់វៀតណាម (១២-៥០០០០នាក់ប្រៀបធៀបនឹងការស្លាប់របស់វៀតណាម ចំនួនស្លាប់រឺរបួសប្រហែល ១០០០០នាក់)ក៏ដោយ ក៏ការបង្វែងកងទ័ពពីកម្ពុជាបានជួយសម្រួលការលេចចេញដ៏ខ្លាំងក្នុងប្រតិបត្តិការកុបកម្មរបស់ខ្មែរក្រហមដែរ ដែលវាធ្វើឱ្យមិនអាចចៀសផុតសម្រាប់របបស.ប.ក.ក្មេងខ្ចីនៅកម្ពុជាឱ្យមានការកែនកងទ័ពនិងតម្រូវឱ្យវៀតណាមដាក់កងទ័ពមួយ ភាគធំរបស់ខ្លួនតាមបណ្ដោយព្រំដែនចិន-វៀតណាម។

នៅក្នុងខណៈពេលនោះ បន្តបន្ទាប់ពីបំបោះបំបង់នៃទីស្ថានអង្គរពួករស់រានខ្មែរដែលនៅសល់មួយចំនួនតិច ជាមួយជំនួយរបស់សៀមបានបង្កើតឡើងរាជធានីថ្មីនៅចម្ងាយច្រើនគីឡូម៉ែត្រទៅភាគអាគ្នេយ៍នៅទីមួយនៃអ្វីដែលឥឡូវគឺភ្នំពេញនេះឯង ។ មជ្ឈមណ្ឌលអំណាចថ្មីនេះបានតាំងនៅចំណុចប្រសព្វគ្នានៃទន្លេមេគង្គនិងទន្លេសាប។ ដូច្នេះ វាបានគ្រប់គ្រងពាណិជ្ជកម្មតាមទន្លេនៃទឹកដីបេះដូងខ្មែរនិងនគរឡាវហើយនិងមានច្រកចូល តាមច្រកនៃដីសណ្តទន្លេមេគង្គទៅកាន់ផ្លូវពាណិជ្ជកម្មអន្តរជាតិដែលបានភ្ជាប់ឆ្នេរសមុទ្រចិនសមុទ្រចិនខាងត្បូងនិងមហាសមុទ្រឥណ្ឌា។ ប្រភេទនៃរដ្ឋនិងសង្គមថ្មីមួយបានផុសឡើងកាន់តែបើកទូលាយចំពោះពិភពលោកខាងក្រៅនិងកាន់តែពឹងផ្អែកលើពាណិជ្ជកម្មតាមរយៈប្រភពភោគទ្រព្យជាងបុព្វការីមុនៗដែលនៅក្នុងដីគោក ។ ទំហំទំហាត់នៃពាណិជ្ជកម្មតាមសមុទ្រជាមួយចិនកំឡុងរជ្ជកាលរាជវង្សមិង(១៣៦៨-១៦៤៤) បានផ្តល់នូវឱកាសរកកម្រៃបានច្រើនចំពោះពួកក្រុមសមាជិកនៃពួកឥស្សរជនខ្មែរដែលជាអ្នកក្តោបក្តាប់ដំណើរការផ្តាច់មុខការដោះដូរពាណិជ្ជកម្មព្រះរាជា ។ការបង្ហាញខ្លួននៃពួកអឺរ៉ុបនៅក្នុងតំបន់នៅក្នុងសតវត្សទីដប់ប្រាំមួយក៏បានលើកស្ទួយដល់វិស័យពាណិជ្ជកម្មដែរ ។

ព្រះបាទអង្គចន្ទ(១៥១៦-១៥៦៦) ជាស្តេចមួយក្នុងចំណោមក្សត្រធំៗខ្មែរពីរបីអង្គនៃសម័យក្រោយអង្គរ បានផ្លាស់រាជធានីពីភ្នំពេញទៅលង្វែក។ ពួកអ្នកដំណើរប៉័ទុយហ្កាល់និងអេស្ប៉ាញដែលអ្នកទាំងនោះបានមកទស្សនាទីក្រុងនេះដែលបានតាំងនៅច្រាំងនៃទន្លេសាប ជាទន្លេមួយនៅភាគខាងជើងភ្នំពេញដែលបានពិពណ៌នារៀបរាប់ទីក្រុង ជាកន្លែងមួយនៃភោគទ្រព្យដ៏សម្បើមអស្ចារ្យ ។ផលិតផលជាច្រើនបានដោះដូរនៅទីនោះរួមមាន ថ្មមានតម្លៃ លោហៈ សូត្រនិងកប្បាស ធូបភ្លុក ម្រ័ក្សណ៍ខ្មុក បសុសត្វ (រួមមានដំរី) និងកុយរមាស(ដែលបានឱ្យតម្លៃដោយពួកចិនជាឱសថកម្រនិងប៉ូវកម្លាំង) ។នៅចុងសតវត្សទីដប់ប្រាំមួយនិងដើមសតវត្សទីដប់ប្រាំពីរលង្វែកមានក្រុមសហគមន៍ពាណិជ្ជកម្មដ៏រីកចម្រើនរបស់ចិនឥណ្ឌូនេស៊ីពួកម៉ាឡេជប៉ុនពួកអារ៉ាប់អេស្ប៉ាញ និងប៉័ទុយហ្កាល់ ។ សហគមន៍ទាំងនេះត្រូវបានចូលរួមក្រោយមកទៀតនៅក្នុងសតវត្សនោះដោយពួកអង់គ្លេសនិងហូឡង់។

នៅក្នុងកំឡុងសម័យកាលនេះ (នៅឆ្នាំ១៥៥៥-១៥៥៦) ដែលពួកបព្វជិតសាសនាគ្រិស្តជាតិប៉័ទុយហ្កាល់ហ្គាសស្ប៉ា ដា គ្រូសហ្ស៍(Gaspar da Cruz)បានធ្វើការព្យាយាមដំបូងដើម្បីផ្សព្វផ្សាយណែនាំគ្រិស្តសាសនាទៅកាន់ប្រទេសនេះ។ តាមរយៈរឿងរ៉ាវផ្ទាល់របស់លោកការខិតខំប្រឹងប្រែងរបស់លោកគឺជាការបរាជ័យទាំងស្រុងដោយសារតែជំនឿស៊ប់លើព្រាហ្មណ៍ខ្លាំងក្លានៃ

ក្សត្រិយ៍និងវណ្ណៈដឹកនាំ ក៏ប៉ុន្តែយ៉ាងណាមិញ របាយការណ៍ខ្លីដែលលោកបានធ្វើបេសកកម្ម ផ្តល់នូវការឆ្លុះបញ្ចាំងទៅក្នុងការគោរពបដិបត្តសាសនាជាតិនៅពេលនោះ ។[២]

ដោយសារតែពួកអ្នកតំណាងនៃសញ្ជាតិទាំងនេះទាំងអស់តាមពិតទៅគឺជាពួកចោរសមុទ្រពួកអ្នកផ្សងព្រេង រឺ ពួកពាណិជ្ជករ ដែលនេះគឺជាសម័យមួយនៃសកលនិយមខ្លាំងក្លា ។ត្រូវបានដាក់សម្ពាធយ៉ាងខ្លាំងដោយពួកសៀម ដើម្បីសងបំណុលវិញ ព្រះបាទសត្ថាទី១(១៥៧៦-៩៤) ដោយនៅជុំវិញខ្លួនទ្រង់មានអង្គរក្សផ្ទាល់ព្រះអង្គជាជាតិអេស្ប៉ាញនិងទាហានស៊ីឈ្នួលប៉័រទុយហ្កាល់ផងហើយនៅឆ្នាំ១៥៩៣ព្រះអង្គបានសុំទេសាភិបាលអេស្ប៉ាញនៅភីលីពីនអោយជួយ ។ ត្រូវបានទាក់ទាញដោយប្រមើលមុននៅការបង្កើតឡើងអាណាព្យាបាលអេស្ប៉ាញនៅកម្ពុជា ហើយនិងការប្តូរទៅរាជាធិបតេយ្យគ្រិស្តសាសនាវិញទេសាភិបាលនេះបានបញ្ជូនកម្លាំងមួយកងដែលមានមនុស្ស១២០នាក់មកក៏ប៉ុន្តែលង្វែកក៏បានធ្លាក់ទៅក្នុងកណ្តាប់ដៃពួកសៀមរួចទៅហើយពេលនោះពួកគេបានមកដល់នៅឆ្នាំបន្ទាប់មកទៀត ។ ពួកអេស្ប៉ាញបានទាញផលប្រយោជន៍នៅក្នុងស្ថានការណ៍ច្របូកច្របល់ដ៏ខ្លាំងក្លានេះដើម្បីលើកមួយនៅក្នុងចំណោមព្រះរាជបុត្ររបស់ព្រះបាទសត្ថាអោយឡើងសោយរាជ្យនៅឆ្នាំ១៥៩៧។ ក្តីសង្ឃឹមនៃការធ្វើអោយប្រទេសនេះជាប្រទេសអាណានិគមអេស្ប៉ាញត្រូវបានបំផ្លាញទៅវិញយ៉ាងណាមិញនៅពេលនោះពួកអេស្ប៉ាញត្រូវបានសម្លាប់រង្គាលនៅពីរឆ្នាំក្រោយមកទៀតដោយគ្មានហេតុផលនៃការប្រទូស្តរាយគ្នាទាំងសងខាងដោយក្រុមទាហានស៊ីឈ្នួលម៉ាឡេ ។

យ៉ាងណាមិញ ពួកសៀមបានពាក់ព័ន្ធនូវការវាយប្រហារដោយយថាហេតុមក លើឯករាជ្យភាពកម្ពុជាដោយកាន់កាប់លង្វែកនៅឆ្នាំ១៥៩៤ ។ ជាមួយនិងការតាំងទ័ពនៃទេសាភិបាលកងទ័ពសៀមម្នាក់នៅក្នុងទីក្រុងកម្រិតនៃការគ្រប់គ្រងនយោបាយបរទេសត្រូវបានបង្កើតឡើងលើរាជាណាចក្រនេះជាលើកទីមួយ ។កាលប្បវត្តិខ្មែរពិពណ៌នាការធ្លាក់ចុះនៃលង្វែកជាគ្រោះមហន្តរាយចាប់ពីនោះមកដែលប្រទេសជាតិនេះមិនដែលបានត្រឡប់មកដូចដើមវិញទាំងស្រុងទេ ។សៀមបានគ្រប់គ្រងកម្ពុជាអស់រយៈពេលស្ទើរតែជិត៣០០ឆ្នាំមកហើយនៅទីបញ្ចប់អង្គរវត្តដែលបាត់បង់មកដល់ពួកបារាំងនៅ១៩០៧បន្ទាប់ពីកាន់កាន់អស់រយៈពេលជាង៤៥០ឆ្នាំមកហើយ ។

............................................................................................................................................



www.facebook.com/7khmer
Fb page : Entertainment And Knowledge